# សង្ឃឹមគ្រប់ពេលវេលា

## សារសម្រាប់ឆ្នាំ ២០២១

មនុស្សជាតិវិវត្តទៅមុខ ព្រោះតែមានមនុស្សច្រើនឥតគណនាសុខចិត្តចែករំលែក ទាំងមានចិត្តសប្បុរស សូម្បីតែក្នុងសម័យដ៏សែនវេទនានេះ។

ក្នុងពេលកន្លងមកនេះ យុវជនយុវនារីមួយចំនួនបាននិយាយមកដល់យើងថា ពួកគេព្រួយបារម្ភអំពីអនាគតរបស់ខ្លួន ៖ តើពួកគេមានសេចក្តីសង្ឃឹមអ្វីសម្រាប់ធ្វើជាទិសដៅក្នុងជីវិត? អំឡុងពេលដែលអ្វីៗទាំងអស់ដូចជារលំទៅហើយ តើពួកគេអាចរំពឹងទុកលើអ្វី? ស៊ីជម្រៅជាងហ្នឹងទៅទៀត តើមានគោលបំណងអ្វីពិតប្រាកដសម្រាប់ជីវិតពួកគេ? ប៉ុន្តែមានអ្នកខ្លះប្រាប់ថា ៖ « កុំអស់សង្ឃឹម ! ចូរចាប់អារម្មណ៍នឹងសញ្ញានៃសេចក្តីសង្ឃឹមវិញ»[1]។

## ចាប់អារម្មណ៍នូវសញ្ញានៃសេចក្តីសង្ឃឹម

ក្នុងសភាពការណ៍ពិភពលោក ដែលរងគ្រោះជម្ងឺរាតត្បាតកូវីដ១៩នេះ យើងឃើញថាមនុស្សកាន់តែច្រើនធ្លាក់ក្នុងភាពក្រីក្រ។ គំរោងការនិងសេចក្តីសម្រេចខាងនយោបាយ

---

[1] សម្រាប់បងប្អូន ដែលមានអាយុពី១៥ ដល់៣៥ឆ្នាំ ហើយដែលចង់ឆ្លើយសារ២០២១នេះ យើងសូមអញ្ជើញបងប្អូន ឲ្យផ្តល់សក្ខីភាពឬឧទាហរណ៍ (ជាការច្នៃប្រឌិតក៏បានឬជារឿងបុគ្គលក៏បាន) ដែលបានបង្កឲ្យខ្លួនមានសេចក្តីសង្ឃឹមឡើងវិញ។ យើងនឹងផ្សាយចម្លើយរបស់បងប្អូននៅពេលខាងមុខនេះ ជាអត្ថបទ ឬជាវីដេអូ ឬជាPodcastsដែរ។ សូមផ្ញើស្នាដៃទៅអាស័យដ្ឋានអ៊ីម៉ែល solidarity@taize.fr ។

សំខាន់ណាស់ ក៏ប៉ុន្តែភាពសាមគ្គីនិងភាតរភាព ដែលមកពីខាងយើង ក៏សំខាន់ដូចគ្នាដែរ។ មានបងប្អូនច្រើនចង់បម្រើអ្នកដទៃ។ ចិត្តសប្បុរសរបស់គេរំលឹកយើងថា មានតែការសហការគ្នា ដែលអាចបើកផ្លូវមួយ សម្រាប់អនាគតរបស់យើង។

យុវជនយុវនារីកាន់តែច្រើនចំណាយកម្លាំងរបស់គេ ដើម្បីការពារភពផែនដី ដែលជាផ្ទះរួមរបស់យើង។ ជាពិសេស ពួកគេកែប្រែរបៀបរស់នៅ កុំអោយបង្កគ្រោះថ្នាក់សម្រាប់បរិស្ថាននិងធម្មជាតិ[2]។ កិច្ចការផ្តួចផ្តើមទាំងអស់នេះជាចំណែកមួយនៃចម្លើយរួមរបស់មនុស្សជាតិ។ ចំពោះអ្នកជឿលើព្រះជាម្ចាស់ ផែនដីជាព្រះអំណោយរបស់ព្រះអង្គ ដែលព្រះអង្គទុកឲ្យយើងថែទាំ។

មនុស្សសម័យឥឡូវនេះកាន់តែយល់យ៉ាងច្បាស់អំពីរចនាសម្ព័ន្ធ ដែលនាំឲ្យមានភាពអយុត្តិធម៌ ក្នុងសង្គម។ ភាពអយុត្តិធម៌ខ្លះជាកេរមរតកពីប្រវត្តិសាស្ត្រ។ ភាពអយុត្តិធម៌ខ្លះ

---

[2]តើយើងអាចរិះគិតអំពីអ្វីដែលយើងអាចផ្លាស់ប្តូរបាន ដើម្បីការពារបរិស្ថាននិងធាតុអាកាស? ក្នុងគ្រប់និកាយគ្រីស្តសាសនា មានសហគមន៍ឬក្រុមជំនុំដែលខំតស៊ូ។ សូមទៅមើលតាមបណ្តាញ Green Churches។

ឆ្នាំ១៩៨៩ សហគមន៍និងក្រុមជំនុំនៅទ្វីបអឺរ៉ុប បានអំពាវនាឲ្យប្រជាជនខិតខំរស់នៅតាមរបៀប ដែលមិនបង្កគ្រោះថ្នាក់ដល់បរិស្ថាន ដូចជាបន្ថយការប្រើប្រាស់ថាមពល(ឧ. អគ្គិសនី, ប្រេង, អុស ។ល។) ធ្វើដំណើរជិះរថយន្តសាធារណៈ(ឧ. ឡានក្រុង) ឬក៏ដូចជាបន្ថយការផលិតសំរាម (ឧ. ចុបប្រើប្រាស់កាប្លាស្ទិក)។

នៅតេហ្សេ យើងខិតខំការពារបរិស្ថានដែរ៖ យើងក៏សូមរង់ចាំយោបល់ពីបងប្អូន។ សូមសរសេរមកយើងតាមគេហទំព័រ www.taize.fr/eco ។

ទៀតមកពីអ្នកកាន់អំណាចមិនបានប្រើអំណាចរបស់ខ្លួន ដើម្បីបម្រើតម្រូវការរបស់សង្គម។ ទង្វើខុសឆ្គងទាំងអស់នេះនាំឲ្យយើងយល់ពីការខកចិត្តនិងកំហឹងរបស់ប្រជាពលរដ្ឋធម្មតា។ តើអ្នកណាសុខចិត្តកសាងយុត្តិធម៌និងសន្តិភាព នៅក្នុងសង្គម ជាពិសេស ដោយជៀសវាងឲ្យមានការបែកបាក់ថែមទៀត?

## អនុវត្តភាតរភាព

ពិតមែន ក្នុងសម័យពោរពេញដោយវិបត្តិនេះ នៅតែមានមូលហេតុដើម្បីសង្ឃឹម សូម្បីតែពេលណាគ្មានសញ្ញានៃសេចក្តីសង្ឃឹមទាល់តែសោះ។ ដើម្បីធ្វើបាន ចូរយើងរួមជាមួយគ្នា គឺរួមជាមួយគ្រីស្តបរិស័ទនិកាយផ្សេងៗ ជាមួយអ្នកកាន់សាសនាដទៃ ជាមួយមនុស្សមិនមានជំនឿ ដើម្បីកសាងភាតរភាពនិងសង្គមចែករំលែក។

ពេលណាយើងរស់នៅដូចជាបងប្អូន ពេលណាយើងស្និទ្ធស្នាលនឹងអ្នកតូចតាច ពេលនោះ អំណរសប្បាយរបស់យើងកាន់តែខ្លាំង។ ការគ្មានជម្រក ភាពចាស់ជរា ជម្ងឺ ភាពឯកា បញ្ហាផ្សេងៗក្នុងការអប់រំកុមារ ពិការភាព ឬការភៀសខ្លួនទៅជាជនអន្តោប្រវេសន៍ គឺ មានកាលៈទេសៈគ្រប់បែបយ៉ាង ដែលអាចធ្វើឲ្យយើងធ្លាក់ចុះក្នុងភាពទន់ខ្សោយ។ ដូចនេះ ជំងឺរាតត្បាត កូវីដ១៩ បង្ហាញថា មនុស្សជាតិទន់ខ្សោយណាស់។

យើងត្រូវការជំនួយពីអ្នកដទៃខ្លាំងណាស់។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ រំលឹកយើង ក្នុងសារលិខិតរបស់លោក (Fratelli tutti) ថា៖ « គ្មាននរណាអាចសង្គ្រោះខ្លួនឯង ដោយផ្ទាល់ខ្លួនបានទេ»។ លោកបន្ថែមថា៖ «គ្មានអ្នកណាអាចរកអត្តសញ្ញាណពិតប្រាកដរបស់ខ្លួន

ឃើញ បើសិនជាមិនបើកចិត្តដល់ពិភពលោក មិនរំភើបនឹងព្រឹត្តិការណ៍ដែលកើតឡើងនៅទីឆ្ងាយ មិនព្រមទទួលពីភាពសម្បូរបែបរបស់វប្បធម៌ផ្សេងៗ ឬមួយទៀត មិនចង់ចូលរួមចំណែកក្នុងវិបដិសារីនៃប្រជាជនដទៃទេ» (កថាខណ្ឌលេខ 32 និងលេខ 146)។

## ជឿ-ទុកចិត្តលើព្រះវត្តមានមួយអង្គ

នៅភូមិតេហ្សេ យើងឃើញថា ដើម្បីរក្សាទិសដៅនៃជីវិត យុវជនយុវនារីមួយចំនួនសួរខ្លួនឯង តាមរបៀបថ្មី អំពីជំនឿលើព្រះជាម្ចាស់ថា៖ តើជឿលើព្រះអង្គមានអត្ថន័យអ្វី? ហើយបើសិនជាមានព្រះជាម្ចាស់ពិតមែន តើព្រះអង្គសកម្មនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្ស និងនៅក្នុងជីវិតរបស់យើងផ្ទាល់ដែរឬ?

ពេលសាកឆ្លើយ កុំឆ្លើយដោយពឹងតែលើគំនិតរបស់ខ្លួន ពីព្រោះព្រះអង្គហួសលើសពីអ្វីដែលអាចគិតនិងស្រមៃ ជាដាច់ខាត។ យើងជាអ្នករក ដែលចង់បានសេចក្ដីស្រឡាញ់និងសេចក្ដីពិត។ យើងទាំងអស់គ្នាកំពុងធ្វើដំណើរតាមផ្លូវវិញ្ញាណ តែទោះជាយើងបានទៅដល់កម្រិតណាក៏ដោយ ជាទូទៅ យើងនៅតែរារែកនិងស្ទាក់ស្ទើរ។ ក៏ប៉ុន្តែ ចូរយើងក្លាយទៅជា "អ្នកធ្វើដំណើរពោរពេញដោយការទុកចិត្ត" ដើម្បីដើរជាមួយគ្នា និងចែករំលែកអ្វីដែលយើងបានរកឃើញ ព្រមទាំងសំណួរ ឬចម្លើយច្បាស់លាស់ផងដែរ។

បងប្រុស Roger ធ្លាប់មានប្រសាសន៍ថា៖ «ជំនឿ គឺដូចជាការទុកចិត្តដ៏សាមញ្ញលើព្រះជាម្ចាស់ ជាការទុកចិត្តដែលបម្រុះខ្លួនរាប់ពាន់ដង តាមកាលៈទេសៈនៃជីវិត សូម្បីតែយើងម្នាក់ៗនៅសង្ស័យនៅឡើយក៏ដោយ»។

ជឿទុកចិត្តបានន័យថាម៉េច? មុនដំបូង មានន័យថា គឺទុកចិត្តលើវត្តមានមួយ (ឬព្រះវត្តមានមួយ!) ដែលកប់នៅក្នុងទីស្ងាត់កំបាំងដួងចិត្តរបស់យើងផង និងគង់នៅទូទាំងសាកលលោកផង ជាព្រះវត្តមានមិនអាចចាប់បានផង តែមានភាពជាក់ស្តែងពិតប្រាកដផងដែរ។ ព្រះវត្តមាននេះមិនបង្ខំយើងទេ តែរាល់ពេលវេលា យើងអាចទទួលព្រះអង្គបាន ក្នុងភាពស្ងប់ស្ងាត់នៃចិត្ត ដូចជាដង្ហើមម្យ៉ាង។ ព្រះវត្តមាននេះពោរពេញដោយសេចក្តីស្រឡាញ់ ដែលនៅជាមួយយើងរហូត សូម្បីតែពេលសង្ស័យ ឬមានអារម្មណ៍មិនសូវយល់ពីព្រះជាម្ចាស់ក៏ដោយ។

## រកឃើញអនាគតថ្មី

ព្រះជាម្ចាស់មានវត្តមានពោរពេញដោយធម៌មេត្តាករុណា។ តើព្រះគម្ពីរដំណឹងល្អពន្យល់ការអាថ៌កំបាំងនេះយ៉ាងដូចម្តេចដែរ?

ព្រះយេស៊ូទទួលកម្លាំងពីព្រះវត្តមាន(របស់ព្រះបិតា) រហូតឥតឈប់ឈរ។ ព្រះអង្គយកចិត្តទុកដាក់អំពីព្រះវត្តមាននេះ គ្រប់ពេលវេលា ពីព្រោះវត្តមាននេះជាពន្លឺ ជាដង្ហើម និងជាខ្យល់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

ពេលព្រះយេស៊ូសោយទុក្ខលំបាក នៅលើឈើឆ្កាង ទ្រង់ជួបវិបដិសារី និងភាពឯកោ។ ពេលនោះ ព្រះអង្គស្រែកហៅទៅកាន់ព្រះបិតាថា៖ «ឱព្រះអម្ចាស់អើយ! ព្រះអម្ចាស់អើយ! ហេតុអ្វីព្រះអង្គបោះបង់ចោលទូលបង្គំដូច្នេះ?» ព្រះអង្គត្រូវគេក្បត់ ធ្វើទណ្ឌកម្មប្រហារជីវិត តែក្នុងយប់អន្ធការនេះ ទ្រង់ក៏បញ្ចូលសេចក្តីស្រឡាញ់។ ហើយសេចក្តី

ស្រឡាញ់នេះខ្លាំងជាងអំពើអាក្រក់ទាំងឡាយ។ នាងម៉ារីពីភូមិម៉ាដាឡា និងក្រុមគ្រីស្ទទូតបានប្រកាសដំណឹងគួរឲ្យឆ្ងល់នោះ គឺថា៖ «ព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញ»។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានឈ្នះការស្អប់និងសេចក្តីស្លាប់។

គ្រីស្តបរិស័ទដើមដំបូងរំភើបចិត្តជាខ្លាំង នៅពេលស្តាប់ឮដំណឹងល្អនេះ ហើយពួកគេផ្តល់សក្ខីភាពថា ឥឡូវនេះ ព្រះគ្រីស្តគង់នៅជិតស្និទ្ធនឹងព្រះជាម្ចាស់។ ព្រះវិញ្ញាណរបស់ព្រះអង្គបំពេញពិភពលោកទាំងមូល ព្រមទាំងចិត្តមនុស្សម្នាក់ៗ។ ព្រះអង្គរួមរស់ជាមួយអ្នកតូចតាច ហើយរកយុត្តិធម៌ឲ្យគេ។ ព្រះគ្រីស្តជាទិសដៅប្រវត្តិសាស្ត្រផង និងទិសដៅស្នាព្រះហស្តទាំងឡាយរបស់ព្រះអង្គផង។ នៅពេលយើងស្លាប់ ព្រះអង្គទទួលយើង នៅក្នុងអំណរសប្បាយដ៏ពេញលក្ខណៈ។ ព្រះអង្គបើកអនាគតថ្មីឲ្យយើង ហួសពីហិង្សារបស់មនុស្ស និងហួសពីឧបទ្រពធម្មជាតិ និងជម្ងឺនានា។ តើពួកយើងអាចមើលឃើញបាន?

## ផ្លាស់ប្តូររបៀបដែលយើងមើលឃើញ

ព្រះគ្រីស្ត ដែលមានព្រះជន្មរស់ឡើងវិញ បើកអនាគតថ្មីឲ្យយើង ហើយផ្តល់ពន្លឺមួយដល់ជីវិតយើង។ ព្រះជន្មថ្មីរបស់ព្រះអង្គកំចាត់ភាពងងឹតនៃការភ័យខ្លាច ធ្វើឲ្យប្រភពទឹកនៃជីវិតផុសឡើង ហើយប្រទានឲ្យយើងច្រៀងកោតសរសើរព្រះជាម្ចាស់ ដោយអំណរសប្បាយ។

ដូច្នេះ យើងអាចដឹង អស់ពីដួងចិត្តថា ព្រះគ្រីស្តបន្តទាញ ហើយប្រមូលមនុស្ស និងពិភពលោក ក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ឥតឈប់ឈរ រហូតដល់អវសានកាល។ ហើយព្រះអង្គឲ្យយើងចូលរួមចំណែកក្នុងបេសកកម្មនេះ។

ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងបំពេញការនេះ រួមជាមួយគ្នា ជាព្រះសហគមន៍តែមួយ។ ដើម្បីធ្វើបាន យើងត្រូវពង្រីកមេត្រីភាពរបស់យើង ឲ្យបានដល់មនុស្សទាំងអស់។ សូម្បីតែខ្មាំងសត្រូវ ក៏ព្រះគ្រីស្តសូមឲ្យយើងស្រឡាញ់គេដែរ។ សន្តិភាព ដែលមកពីព្រះអង្គ អាចផ្សះផ្សាជនជាតិដែលជាសត្រូវគ្នា ឲ្យទៅជាធ្លុងតែមួយ[3]។

---

[3] ក្នុងពេលដ៏ពិបាកដែលវីរុសកូវីដកំពុងតែវាយលុក ព្រះសហគមន៍នៅតែបន្តលើកតម្កើងភាតរភាពរបស់ក្រុមគ្រួសារមនុស្សជាតិ។ នេះជាយោបល់ខ្លះដែលអាចធ្វើបាន ៖

-ដើម្បីឲ្យសង្គមរបស់យើងប្រកបដោយធម៌មេត្តាករុណាកាន់តែច្រើន យើងត្រូវស្តាប់គ្នាទៅវិញទៅមក ជាពិសេសដោយគ្មានបុរេនិច្ឆ័យ ហើយហ៊ានធ្វើដំណើររួមជាមួយគ្នា ដោយទទួលស្គាល់ភាពខុសគ្នារវាងគ្នា។ តើបងប្អូនដែលមិនមែនជាគ្រីស្តបរិស័ទអាចយល់ព្រមសន្ធនាជាមួយព្រះសហគមន៍ដែរឬ?

-សព្វថ្ងៃ ជនអន្តោប្រវេសន៍ ឬអ្នកភៀសខ្លួន បានសុំមកនៅក្នុងប្រទេសយើង។ ការទទួលមនុស្សម្នាក់ឬគ្រួសារមួយដែលជាជនភៀសខ្លួន ក្នុងព្រះសហគមន៍ឬក្រុមជំនុំ អាចផ្តល់កម្លាំងថ្មីឲ្យយើង។ មនុស្សមួយចំនួនដែលមិនធ្លាប់មកព្រះវិហារក៏អាចឆ្លៀតឱកាស ចូលរួមក្នុងការងារនេះ ដើម្បីជួយគ្នា។ នេះជាបទពិសោធន៍របស់យើងនៅភូមិតេហេ្ស ដែលយើងរួមជាមួយប្រជាជនក្នុងខេត្តយើង ដើម្បីទទួលជនភៀសខ្លួនពីច្រើនប្រទេស។

-បើយើងចង់បង្កើតផ្ទះកក់ក្តៅ ក៏យើងត្រូវតែយកចិត្តទុកដាក់ស្តាប់អ្នកដែលទន់ខ្សោយជាងគេ។ ជាទូទៅ ព្រះសហគមន៍ត្រូវតែខិតខំព្យាយាមថែមទៀត ដើម្បីការពារតម្លៃរបស់មនុស្សទាំងអស់។ ជួនណា របៀបដែលព្រះសហគមន៍ប្រើអំណាច បានបង្កឲ្យអ្នកខ្លះរងទុក្ខលំបាក តាមផ្លូវកាយ តាមផ្លូវចិត្ត និងតាមផ្លូវវិញ្ញាណ។ ដូច្នេះនៅតេហេ្ស យើងខិតខំព្យាយាមរិះគិតពីចារណា ដើម្បីស្គាល់ខ្លួនឯងកាន់តែច្បាស់ ហើយមិនជៀសវាងសេចក្តីពិតផង។

ចូរទុកឲ្យព្រះគ្រីស្តផ្លាស់ប្តូររបៀបមើលឃើញរបស់យើង៖ ពេលយើងរួមជាមួយព្រះអង្គ យើងទទួលស្គាល់តម្លៃរបស់មនុស្សម្នាក់ៗ និងសោភ័ណភាពនៃធម្មជាតិ កាន់តែច្បាស់ឡើងៗ។ សេចក្តីសង្ឃឹមមិនមែនជាការទុកចិត្តស៊ុប ក៏ប៉ុន្តែដោយមានគ្រឹះលើព្រះគ្រីស្ត សេចក្តីសង្ឃឹមអាចកើតឡើង ម្តងហើយម្តងទៀត ឥតឈប់ឈរ។ យើងមានអំណរដ៏លើសលប់ ដែលធ្វើឲ្យយើងមានចិត្តក្លាហាន ដើម្បីទទួលការខុសត្រូវ ដែលព្រះជាម្ចាស់បានប្រទានឲ្យយើងបំពេញ នៅលើផែនដីនេះ។

ខ្ញុំសូមបញ្ជាក់ដល់អស់អ្នក ដែលអានសារនេះថា ខ្ញុំនឹងរួមអធិដ្ឋានជាមួយគ្នា។

fr. Alois

*ឱ ព្រះយេស៊ូគ្រីស្តអើយ ! យើងខ្ញុំសូមលើកតម្កើងព្រះអង្គ សម្រាប់ធម៌មេត្តាករុណា និងព្រះហឫទ័យសាមញ្ញរបស់ព្រះអង្គ។ អស់មួយជីវិតរបស់ព្រះអង្គ ព្រះហឫទ័យសុភាពរាបសារនេះបានបញ្ចាំងពន្លឺរបស់ព្រះជាម្ចាស់ គឺពន្លឺហ្នឹងដែលភ្លឺក្នុងបេះដូងរបស់យើងខ្ញុំថ្ងៃនេះ។ ពន្លឺនេះអាចព្យាបាលមុខរបួសរបស់យើងខ្ញុំ និង បម្លែងភាពទន់ខ្សោយ ឬភាពសង្ស័យរបស់ខ្លួន ឲ្យទៅជាប្រភពម្យ៉ាង ឬថាមពលកែឆ្នៃ ឬទំនុកចិត្តដែលជាអំណោយទានរបស់ព្រះអង្គ។ ដោយពន្លឺរបស់ព្រះជាម្ចាស់បំភ្លឺយើងខ្ញុំ ព្រះអង្គប្រោសប្រទានឲ្យយើងខ្ញុំសង្ឃឹមគ្រប់ពេលវេលា។*

**អត្ថបទគម្ពីរខ្លះនេះអាចជួយយើងឲ្យសញ្ជឹងគិតកាន់តែស៊ីជម្រៅ៖**

**ព្រះនាងម៉ារីធ្លាប់ច្រៀងថា ៖ «ទ្រង់បានសម្តែងឫទ្ធិបារមី កំចាត់មនុស្សដែលមានចិត្តឆ្មើងឆ្មៃ ទ្រង់បានទម្លាក់អ្នកកាន់អំណាចចុះពីតំណែង ហើយទ្រង់លើកតម្កើងមនុស្សទន់ទាបឡើង» (លក.១,៤៦-៥៦)។**

ព្រះនាងម៉ារី ម្តាយព្រះយេស៊ូ សង្ឃឹមខ្លាំងៗថា គង់តែមានការផ្លាស់ប្តូរយ៉ាងពេញលេញនៃស្ថានភាពរស់នៅរបស់មនុស្ស ក៏ប៉ុន្តែការផ្លាស់ប្តូរនោះត្រូវពោរពេញដោយសេចក្តីស្រលាញ់និងភាពទន់ភ្លន់។

**ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ព្រះដ៏ជួយការពារ គឺព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះបិតាចាត់ឲ្យមកក្នុងនាមខ្ញុំ នឹងបង្រៀនសេចក្តីទាំងអស់ដល់អ្នករាល់គ្នា ព្រមទាំងរំលឹកអ្វីៗដែលខ្ញុំបានប្រាប់អ្នករាល់គ្នាផង» (យហ. ១៤,១៥-៣១)។**

ព្រះយេស៊ូមិនបោះបង់ចោលយើងឲ្យម្នាក់ឯងបានទេ។ មុនសោយទិវង្គត ព្រះអង្គបានបញ្ជាក់យ៉ាងច្បាស់ថា ទ្រង់នឹងគង់ជាមួយសាវ័កជានិច្ចរហូត តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះអង្គរស់ក្នុងយើង លើកទឹកចិត្តយើង គាំទ្រយើង ហើយបំភ្លឺយើង ដើម្បីឲ្យយើងដើរតាមព្រះយេស៊ូ ជារៀងរាល់ថ្ងៃ។

**«ចូរអោយផ្ទៃមេឃមានអំណរសប្បាយ ! ចូរអោយផែនដីបានរីករាយឡើង ហើយសមុទ្រនិងអ្វីៗដែលស្ថិតនៅក្នុងសមុទ្របន្លឺសំឡេងយ៉ាងអឺងកង ! ចូរអោយស្រែចំការនិងអ្វីៗដែលស្ថិតនៅទីនោះត្រេកអរសប្បាយ ! ចូរអោយព្រៃព្រឹក្សាទាំងប៉ុន្មានស្រែកហ៊ោនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ ដ្បិតព្រះអង្គយាងមកហើយ ព្រះអង្គយាងមកវិនិច្ឆ័យទោសផែនដី ព្រះអង្គវិនិច្ឆ័យទោសផែនដីដោយយុត្តិធម៌» (ទន. ៩៦)។**

ទំនុកតម្កើងភាគច្រើនអញ្ជើញយើងឲ្យកោតសរសើរព្រះជាម្ចាស់ មិនគ្រាន់តែប៉ុណ្ណោះសោត គឺអញ្ជើញធម្មជាតិទាំងមូល ដែលជាស្នាព្រះហស្តរបស់ព្រះអង្គ ឲ្យចូលរួមចំណែកដែរ។ យើងមិនចង់ការពារធម្មជាតិ ពីព្រោះយើងត្រូវការធម្មជាតិ ដើម្បីរស់នៅមានជីវិត គឺយើងចង់ការពារធម្មជាតិ ពីព្រោះយើងជាផ្នែកមួយនៃធម្មជាតិផង ហើយព្រះហឫទ័យប្រណីសណ្ដោសរបស់ព្រះអង្គក៏គ្រប់គ្រងលើជីវិតគ្រប់បែបយ៉ាងផងដែរ។